ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពត**

*សំណុំរឿងព្រហ្មទណ្ឌ*

លេខ៖ ៨៧៤

ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

*សំណុំរឿងជម្រះ*

លេខ៖ ៦៦៩

ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

*សាលក្រមព្រហ្មទណ្ឌ*

លេខ៖ ១០៦ " ឃ "

ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកំពត

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកំពត

បើកសវនាការនៅ ថ្ងៃទី០២ ខែ កុម្ភៈ ឆ្នាំ២០២៤

ប្រកាសសាលក្រមនៅ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤

ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ឋានៈអនុប្រធាន ជាចៅក្រមជំនុំជម្រះ

## តំណាងអយ្យការ

លោកស្រី [redacted] ឋានៈព្រះរាជអាជ្ញារង ជាតំណាងអយ្យការ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

## មេធាវី

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សារៀម ហៅ ស្រីទូច

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អូន

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៧៤ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ភេទស្រី អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត និងមានទីលំនៅប[redacted] ខេត្តកំពត មុខរបរអាជីវករ ប្តីឈ្មោះ [redacted] ម៉ង់ (រ) មានកូន០២នាក់ ឪពុកឈ្មោះ [redacted] មករា (រ) , ម្តាយឈ្មោះ [redacted] សាឌុន (រ) , ទោសពីមុន គ្មាន ។

ជាប់ចោទពីបទ៖ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅខេត្តកំពត កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អួន ភេទស្រី អាយុ៦០ឆ្នាំ មានអាសយដ្ឋាននៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត ។

## អង្គហេតុនៃរឿងមានដូចតទៅ ៖

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ ស្ថិតនៅខេត្តកំពត មានករណី **បរិហារកេរ្តិ៍ជាសាធារណៈ** បង្កឡើងដោយឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ភេទស្រី អាយុ៤៥ឆ្នាំ ដោយបានផ្ញើសារសម្លេងទៅគណនីបណ្តាញសង្គមហ្វេសប៊ុក (Facebook) ឈ្មោះ [redacted] Lern តាមរយៈឆាត ហើយឈ្មោះ [redacted] Lern បានឡាយ (Live) តាមហ្វេសប៊ុក (Facebook) ដោយបានចាក់សារសម្លេងនោះ ដោយនិយាយអំពីជនរងគ្រោះឈ្មោះ [redacted] អួន ភេទស្រី កើតឆ្នាំ១៩៦៣ ដោយចាក់សម្លេងដែលឈ្មោះ [redacted] សារៀម ហៅ ស្រីទូច និយាយប្រាប់ថា “ **យាយអួនគាត់នៅហ្នឹង ហើយតុលាការនៅហ្នឹងគាត់ជាជំនួយការមេធំហ្នឹង យាយហ្នឹងពីមុនឬកណាស់ ឬកមាំណាស់ទើបអស់ផ្ទង់ហ្នឹងទេបានរៀងនៅ ណេបនើបៗ ពីមុនម៉ោ ម៉ែអើយល្បីទូទាំងខេត្តកំពត** ” និងនិយាយថា “ **បងស្រីអួនគាត់អ្នកនៅពីក្រោយរឿងទាំងអស់ហ្នឹងនៅតុលាការ ប៉ុន្តែឥឡូវគេដកបងហ្នឹងចោលហើយនៅតុលាការគាត់អត់មានមុខមាត់អីទៀតទេគេដកចោលហើយ** ” ។ ឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ក៏បាននិយាយឱ្យឈ្មោះ [redacted] Lern ថា “ **ដាក់ឱ្យធំៗទៅអួនសម្លាញ់នៅស្រណោះ នៅអីទៀតដាក់ទៅអួនសម្លាញ់** “ ហើយឈ្មោះ [redacted] Lern ក៏បានចាក់សារសម្លេងរបស់ឈ្មោះ [redacted] សារៀម ហៅ ស្រីទូច និយាយថា “ **រឿងនៅកំពតទាំងអស់បង [redacted] អួន អ្នកកាន់ឱ្យវារឿងគ្រប់បែបយ៉ាងហ្នឹងវាការពារ** ” ដែលទង្វើនេះធ្វើឱ្យប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះយ៉ាងធ្ងន់ធ្ងរ ។ ក្រោយមកឈ្មោះ [redacted] អួន ក៏បានដាក់ពាក្យបណ្តឹងមកអយ្យការដើម្បីចាត់ការទៅតាមនីតិវិធី ។

## នាពេលសវនាការ

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ។

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អួន ។

-តុលាការឱ្យក្រឡាបញ្ជីអានកំណត់ហេតុចម្លើយរបស់សាក្សីឈ្មោះ [redacted] សារឿន ។

-មេធាវីការពារសិទ្ធឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អួន បានបញ្ជាក់ថា៖ កូនក្តីខ្ញុំបានចូលឆ្លើយបំភ្លឺតាមនីតិវិធីតុលាការ ដោយបានឆ្លើយនៅដំណាក់កាលអយ្យការថា ករណីនេះគឺជាការកាត់សំឡេងកូនក្តីរបស់ខ្ញុំ និងយកទៅធ្វើការផ្សព្វផ្សាយជាសាធារណៈតាមការឡាយវីដេអូលើគេហទំព័រហ្វេសប៊ុក ម្យ៉ាងទៀតជនជាប់ចោទត្រូវតែមានវត្តមាននានីតិវិធីសវនាការ តែជនជាប់ចោទបែរជាមិនចូលរួមដោយលើកមូលហេតុថារស់នៅរាជធានីភ្នំពេញ តែមិនមានឯកសារណាមួយបញ្ជាក់នោះទេ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អួន ៖ កូនក្តីខ្ញុំបានបញ្ជាក់ថានៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ មានគណនីហ្វេសប៊ុកឈ្មោះ [redacted] Lern បានយកសំឡេងដែលជនជាប់ចោទឈ្មោះ [redacted] សារៀម ផ្ញើឱ្យខ្លួន និងបានយកសំឡេងនោះមកធ្វើចាក់ក្នុងការ Live ផ្ទាល់របស់ខ្លួន ដោយសំឡេងដែលបានយកមកចាក់នោះគឺជាសំឡេងដែលនិយាយថា “យាយអួនគាត់នៅហ្នឹង ហើយតុលាការនៅហ្នឹងគាត់ជាជំនួយការមេធំហ្នឹង យាយហ្នឹងពីមុនឬកណាស់ ឬកមាំណាស់ទើបអស់ផ្ទង់ហ្នឹងទេបានរៀងនៅ ណេបនើបៗ ពីមុនម៉ោ ម៉ែអើយល្បីទូទាំងខេត្តកំពត” និងនិយាយថា “បងស្រីអួនគាត់អ្នកនៅពីក្រោយរឿងទាំងអស់ហ្នឹងនៅតុលាការ ប៉ុន្តែឥឡូវគេដកបងហ្នឹងចោលហើយនៅតុលាការគាត់អត់មានមុខមាត់អីទៀតទេគេដកចោលហើយ” ដែលធ្វើឱ្យប៉ះពាល់ដល់



Scanned with CamScanner

កិត្តិយសរបស់កូនក្តីខ្ញុំយ៉ាងធ្ងន់ធ្ងរ ។ ចំពោះឈ្មោះ [redacted] សារឿម និង [redacted] Lern គឺជាមនុស្សដែលស្គាល់គ្នា ហើយការដែលជនជាប់ចោទថាការយកសំឡេងទៅចាក់ផ្សាយនោះជាការកាត់តសំឡេងរបស់គាត់តើគាត់មានភស្តុតាងមកបញ្ជាក់ទេ? ចំពោះចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលអយ្យការគឺគាត់បានឆ្លើយថាគាត់គឺជាអ្នកនៅពីក្រោយរឿងនេះ ហើយគាត់ពិតជាបានប្រាប់ឈ្មោះ [redacted] Lern ពិតមែន ហើយរឿងរបស់គាត់ជាមួយ កំពតនារី សូមកុំអូសគាត់ទៅពាក់ព័ន្ធ ។ ហើយបើថាសំឡេងនោះជាសំឡេងកាត់ត តើកាត់តតាមណាបើកំពុងតែធ្វើការLiveលើហ្វេសប៊ុកនោះ ហើយពេលដែលខ្ញុំកំពុងមើលការLive នោះក៏មានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទកំពុងតែមើល Liveនោះផងដែរ ។ ជនជាប់ចោទបានដឹងគ្រប់រឿងពីកូនក្តីខ្ញុំ ហេតុនេះតើគាត់មានចេតនាឬយ៉ាងណាមកលើកូនក្តីខ្ញុំ? ម្យ៉ាងទៀតមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទក៏បានសុំធ្វើការចរចាជាមួយកូនក្តីខ្ញុំ ហេតុនេះបើជនជាប់ចោទមិនបានប្រព្រឹត្តហេតុអ្វីគាត់សុំចរចា ហេតុនេះបើភាគីខាងជនជាប់ចោទចង់ដោះបន្ទុកគួរតែរកភស្តុតាងដើម្បីបញ្ជាក់ថាសំឡេងនោះមិនមែនជាសំឡេងរបស់ខ្លួនមិនមែនមកសុំធ្វើការចរចានោះទេ ដែលជាហេតុឱ្យឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ។ ហេតុនេះករណីនេះគឺធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍កូនក្តីខ្ញុំយ៉ាងធ្ងន់ធ្ងរ ។ ក្នុងរឿងនេះសូមតុលាការផ្តន្ទាទោសពិន័យជាប្រាក់លើជនជាប់ចោទជាអតិបរមា និងសូមទាមទារសំណងដែលជនជាប់ចោទបានធ្វើឱ្យកូនក្តីខ្ញុំឈឺចាប់ ក្នុងនាមជាអតីតមន្ត្រីរាជការ ដែលធ្វើឱ្យកូនក្តីខ្ញុំឈឺចាប់យ៉ាងខ្លាំង ហេតុនេះសូមទាមទារសំណងចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ជនជាប់ចោទបានអវត្តមាននានីតិវិធីសវនាការតែបានទទួលដីកាកោះហៅចូលរួមក្នុងនីតិវិធីសវនាការរួចហើយ ហើយជនជាប់ចោទបានថាសំឡេងនោះជាសំឡេងកាត់ត តែជនជាប់ចោទមិនមានភស្តុតាងណាមួយដើម្បីដោះបន្ទុកនោះទេ ហេតុនេះតំណាងអយ្យការនៅតែយល់ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ដូចនេះសូមតម្កល់ការចោទប្រកាន់ដូចក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងសុំឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សារឿម ៖ ខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សារឿម សូមស្នើសុំឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទប្រកាន់ ព្រោះផ្អែកតាមពាក្យបណ្តឹងរបស់លោកស្រី [redacted] អូន និងផ្អែកតាមចម្លើយរបស់លោកស្រី [redacted] អូន ថាមានគណនីហ្វេសប៊ុកឈ្មោះ [redacted] Lern បានធ្វើការ Live និងបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់គាត់ ប៉ុន្តែករណីនេះគឺធ្វើឡើងដោយគណនីហ្វេសប៊ុកឈ្មោះ [redacted] Lern ប៉ុន្តែមិនមែនធ្វើឡើងដោយគណនីហ្វេស៊ុកកូនក្តីខ្ញុំនោះទេ ហើយកូនក្តីខ្ញុំក៏ជាជនរងគ្រោះដែលកើតឡើងពីការថតសំឡេងឯកជន ។ ករណីនេះគឺមានកង្វះធាតុផ្សំនៃបទល្មើស ព្រោះជាមូលដ្ឋាននៃបទល្មើសបរិហារកេរ្តិ៍ជាសាធារណៈ គឺការនិយាយតាមមធ្យោបាយណាមួយជាសាធារណៈ ប៉ុន្តែកូនក្តីខ្ញុំមិនបានធ្វើសកម្មភាពបែបនេះទេ ព្រោះការLive ជាសាធារណៈជាគណនីហ្វេសប៊ុករបស់ឈ្មោះ [redacted] Lerm នោះទេ មិនមែនជាគណនីហ្វេសប៊ុករបស់កូនក្តីខ្ញុំឡើយ ហេតុនេះកូនក្តីខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ព្រោះខ្វះធាតុផ្សំនៃបទល្មើសដែលជាធាតុនីត្យានុកូល ដូចនេះសូមឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានជាបន្តថា៖ ការលើកឡើងថាសូមឱ្យជនជាប់ចោទរួចផុតរួចផុតពីបទចោទ ដោយផ្អែកតាមចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលអយ្យការដែលថាគាត់មិនមែនជាអ្នក Live ផ្ទាល់ទេ តែសំឡេងដែលបានចាក់នៅក្នុងការ Live គឺជាសំឡេងរបស់គាត់ ហេតុនេះបញ្ជាក់ឱ្យ



Scanned with CamScanner

ឃើញថាជនជាប់ចោទបានធ្វើការបរិហារកេរ្តិ៍លើក្លូវឡេរ្ឋចបាត់ទៅហើយមុននឹងគេយកទៅធ្វើការLiveទៅទៀត ហើយបានបដិសេធថាខ្លួនមិនបាននិយាយ ។ ចេតនារបស់ជនជាប់ចោទគឺមិនបានដឹងកំហុសរបស់ខ្លួន ដែលខ្លួនបានផ្តល់សំឡេងឱ្យគេ ដែលនាំឱ្យឈ្មោះ [redacted] Lern ដែលជាអ្នករស់នៅអាមេរិកបានធ្វើការ Live តាមគណនីហ្វេសប៊ុកធ្វើឱ្យប៉ះពាល់ដល់កូនក្តីខ្ញុំ ។ ហើយអ្នកស្រី [redacted] សារៀម ក៏បានចូលមកសូមទោសកូនក្តីខ្ញុំ និងបានណាត់ជួបដើម្បីចរចាផងដែរតែក្រោយមកគាត់ដែលជាអ្នកណាត់ក៏មិនបានមកវិញ ។ ហេតុនេះរហូតមកដល់ពេលនេះគឺមិនមានភស្តុតាងដោះបន្ទុកណាមួយទេ ហេតុនេះសូមសំណូមពរដូចការទាមទារខាងលើទុកជាបានការដដែល ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានជាបន្តថា៖ ចំពោះភស្តុតាងដែលត្រូវបញ្ជាក់គឺខាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវរកភស្តុតាងដើម្បីបញ្ជាក់ថាជាការពិត ហើយកូនក្តីខ្ញុំមិនមែនជាអ្នកប្រព្រឹត្តសកម្មភាពនោះឡើយ ។ ហើយការដែលលើកឡើងថាកូនក្តីខ្ញុំបានផ្តល់សំឡេងឱ្យគេ តើមានភស្តុតាងបញ្ជាក់ទេ ហើយហេតុអ្វីបានជាគាត់មិនប្តឹងអ្នកដែលបានធ្វើការLiveនោះតែម្តងទៅ ព្រោះគាត់ដឹងថាអ្នកដែលបានធ្វើសកម្មភាពនោះគឺនៅបរទេស ។ ហេតុនេះខ្ញុំនៅតែសូមបញ្ជាក់ថាអំពើនេះគឺប្រព្រឹត្តដោយឈ្មោះ [redacted] Lern មិនមែនកូនក្តីខ្ញុំនោះទេ ។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានជាបន្តថា៖ អ្នកដែលមានតួនាទីដោះបន្ទុកគឺភាគីខាងជនជាប់ចោទមិនមែនកូនក្តីខ្ញុំនោះទេ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានជាបន្តថា៖ ការចោទប្រកាន់របស់តំណាងអយ្យការ គឺដោយសារតែគាត់មានតម្រុយពីបទល្មើសទើបគាត់បញ្ជូនរឿងមកជំនុំជម្រះ ហេតុនេះមិនអាចសន្មតថាកូនក្តីខ្ញុំមានទោសនោះទេ ។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានជាបន្តថា៖ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនៅតែអះអាងថាកូនក្តីគាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ដោយលើកឡើងអំពីបញ្ហាផ្លូវច្បាប់ ប៉ុន្តែតាមចម្លើយរបស់កូនក្តីគាត់ដែលបានឆ្លើយនៅដំណាក់កាលអយ្យការគឺជនជាប់ចោទបានទទួលស្គាល់ថាគាត់ពិតជាបាននិយាយ ហើយជនជាប់ចោទក៏បានផ្តិតមេដៃលើកំណត់ហេតុនោះផងដែរ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ការលើកឡើងពីសារសំឡេង ការដោះបន្ទុកជាកាតព្វកិច្ចរបស់ជនជាប់ចោទ ហេតុនេះយើងត្រូវរកសាក្សី ដើម្បីយកចម្លើយរបស់សាក្សីមកដោះបន្ទុកជាដើម ។ ហេតុនេះតំណាងអយ្យការបានពិនិត្យលើសំណុំរឿងរួចហើយទើបបញ្ជូនមកជំនុំជម្រះ ។ ហើយចំពោះការលើកឡើងអំពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺត្រឹមត្រូវ ប៉ុន្តែយើងត្រូវពិនិត្យទៅលើមាត្រា២៦ នៃក្រមព្រហ្មទណ្ឌផងដែរ ដែលពាក់ព័ន្ធនឹងសហចារី ដែលគាត់បានចូលរួមប្រព្រឹត្តបទល្មើសក្នុងនាមជាសហចារី ។ ការលើកឡើងថាមិនមែនជាការផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែការបង្ហោះនោះគឺដាក់ជា Public ហេតុនេះវាជាការផ្សាយជាសាធារណៈហើយ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សារៀម ។
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] អូន ។
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] សារឿន ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីកាការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។



Scanned with CamScanner

• ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារ និងកំណត់ហេតុផ្សេងៗ ។

• ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តកំពត
## យល់ឃើញថា

១/ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ២៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ របស់តំណាងអយ្យការ នៃអយ្យការអមសាលាដំបូងខេត្តកំពត សម្រេចបញ្ជូនសំណុំរឿងមកជំនុំជម្រះ ដែលមានជនជាប់ចោទឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ។

២/ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អូន ដែលបានឆ្លើយនៅដំណាក់កាលអយ្យការ បានបញ្ជាក់ថា៖ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០ នាទីយប់ មានគណនីហ្វេសប៊ុកឈ្មោះ [redacted] Lern បានធ្វើការឡាយ (Live) តាមបណ្តាញសង្គមហ្វេសប៊ុក ដោយបានចាក់សម្លេងឆ្លងឆ្លើយជាមួយគណនីហ្វេសប៊ុកឈ្មោះ ស្រីទូច ដោយក្នុងខ្លឹមសារនៃការឆ្លងឆ្លើយគ្នានោះគឺបានធ្វើការបរិហារកេរ្តិ៍លើខ្លួន និងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ខ្លួនយ៉ាងធ្ងន់ធ្ងរ ហេតុនេះសូមទាមទារសំណងចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក និងសូមឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៣/ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ដែលបានឆ្លើយនៅដំណាក់កាលអយ្យការ បានបញ្ជាក់ថា៖ ខ្លួនពិតជាមានទំនាក់ទំនងជាមួយគណនីហ្វេសប៊ុក [redacted] Lern ពិតមែន ដោយបានធ្វើការឆាត (Chat) ឆ្លងឆ្លើយគ្នាពិតមែន ព្រមទាំងបានទទួលស្គាល់នូវពាក្យមួយចំនួនដូចជាពាក្យដែលថា "យាយអូនគាត់នៅកាលហ្នឹង ហើយតុលាការនៅហ្នឹងគាត់ជាជំនួយការមេធំហ្នឹង" និងពាក្យថា "យាយហ្នឹងពីមុនឫកណាស់ ឫកមាំណាស់ទើបតែអស់ផ្ទង់ហ្នឹង ទេបានរៀងនៅ ណេបនើបៗ ពីមុនម៉ោ ម៉ែអើយល្បីទូទាំងខេត្ត" តែឃ្លានេះគឺខ្លួនបាននិយាយថា ខ្លួនបានឮគេនិយាយតៗគ្នាមកដែរទេ ហើយខ្លួនក៏បានប្រាប់ទៅឈ្មោះ [redacted] Lern ថា "តែពិត ឬមិនពិតខ្លួនមិនដឹងទេអូនអើយ) រួចឈ្មោះ [redacted] Lern ក៏បានកាត់សំឡេងនេះចូលគ្នានាំឱ្យមានការយល់ច្រឡំតែម្តង ។ ហើយចំពោះពាក្យផ្សេងទៀតដែលមានក្នុងអង្គហេតុគឺខ្លួនមិនបាននិយាយនោះទេ ។

៤/ តាមចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿង យល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ហើយជនជាប់ចោទមិនមានភស្តុតាងណាមួយដើម្បីដោះបន្ទុកនោះទេ ។

៥/ ជនជាប់ចោទឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ជានីតិជន មានសតិសម្បជញ្ញៈ និងសមត្ថភាព គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៦/ មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើ ជនជាប់ចោទឈ្មោះ [redacted] សារៀម ហៅ ស្រីទូច ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅខេត្តកំពត កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

៧/ អំពើដែលជនជាប់ចោទឈ្មោះ [redacted] សារៀម ហៅ ស្រីទូច បានប្រព្រឹត្ត គឺធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម និងជាពិសេសគឺធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ។



Scanned with CamScanner

៨/ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ បានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted]សារៀម ហៅ ស្រីទូច ពីបទ **បរិហារកេរ្តិ៍ជាសាធារណៈ** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ នោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការលើកយកពិចារណា ។

៩/ ដើមបណ្តឹងរដ្ឋប្បវេណីបាន ប្តឹងទាមទារសំណងពីជនជាប់ចោទចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក គប្បីតុលាការពិចារណាផ្តល់សំណងសមរម្យដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

## <u>ហេតុដូច្នេះសម្រេច</u>

១. ផ្តន្ទាទោសពិន័យជាប្រាក់លើជនជាប់ចោទឈ្មោះ [redacted]**សារៀម ហៅ ស្រីទូច** ភេទស្រី អាយុ៤៥ឆ្នាំ (សាវតារជាតិដូចខាងលើ) ចំនួន ***៤.០០០.០០០ (បួនលាន) រៀល ចូលជាថវិការដ្ឋ។***

ពីបទ **បរិហារកេរ្តិ៍ជាសាធារណៈ** ប្រព្រឹត្តនៅខេត្តកំពត កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

២. បង្គាប់ឱ្យជនជាប់ចោទ ឈ្មោះ [redacted] **សារៀម ហៅ ស្រីទូច** សងសំណងជំងឺចិត្តឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អូន** ចំនួន ***១០.០០០.០០០ (ដប់លាន) រៀល ការទាមទារលើសពីនេះបដិសេធចោល ។***

៣. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចាត់ទុកចំពោះមុខជនជាប់ចោទ និងចាត់ទុកចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កំពត,ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤
**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner